# សេចក្តីថ្លែងការណ៍រួម
# ស្តីពី
# ការស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជា លុបចោលអាជ្ញាប័ណ្ណនាំចេញឈើទៅបរទេស
# របស់ក្រុមហ៊ុនអង្គរផ្លាយវូត ខូ អិលធីឌី

*ភ្នំពេញ, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣*

សមាគម អង្គការមិនមែនរដ្ឋាភិបាល សហជីព សហគមន៍មូលដ្ឋាន និងក្រុមយុវជន មានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង ក្រោយទទួលបានព័ត៌មានពីការស្នើសុំពន្យាពេលនាំឈើចេញរយៈពេល ៥ឆ្នាំបន្ថែមទៀតរបស់ក្រុមហ៊ុន អង្គរផ្លាយវូត ខូ អិលធីឌី ចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៦។ យោងតាមការចុះផ្សាយរបស់វិទ្យុអាស៊ីសេរី កាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៣ ក្រោមចំណងជើង "ក្រុមហ៊ុនអង្គរផ្លាយវូតនៅតែបន្តនាំចេញឈើកម្រទៅលក់នៅក្រៅប្រទេស[1]" ដែលបានចុះផ្សាយពីការអនុញ្ញាតរបស់ទីស្តីការគណៈរដ្ឋមន្រ្តីសម្រេចពន្យាពេលនៃការនាំឈើចេញ រហូតដល់ដំណាច់ឆ្នាំ២០២៣ តបតាមការស្នើសុំរបស់ក្រុមហ៊ុន នេះ ដែលបានស្នើសុំពន្យាពេលនាំឈើចេញរយៈពេល៥ឆ្នាំបន្ថែម។

យោងតាមសេចក្តីសម្រេចលេខ ៧៣៩ ស.ជ.ណ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យក្រុមហ៊ុនអង្គរផ្លាយវូត ខូ អិលធីឌី ទទួលបានការពន្យាពេលនាំចេញផលិតផលឈើកែច្នៃចំនួន ១០៣ ៧៦៣,១៥ម៉ែត្រគូប ដែលនៅសល់ពីការអនុញ្ញាតកាលពីឆ្នាំ២០១៦ ឱ្យបន្តការនាំចេញរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។[2] ការអនុញ្ញាតរបស់រាជរដ្ឋាភិបាលខាងលើនេះ បានឱ្យនាំចេញតែប្រភេទឈើកែច្នៃ ដូចជា ក្តារបន្ទះ ក្តារកម្រាលការ៉ូ និងផលិតផលកែច្នៃផ្សេងៗទៀតដែលផលិតពីឈើកិន[3] (Core Veneer) តែផ្ទុយទៅវិញក្រុមហ៊ុនបាននាំចេញឈើកម្រជាច្រើនប្រភេទដូចជា ស្រឡៅ កកោះ ធ្នឹក សុក្រមជាដើម ចំនួន ២,២៣៥,៨៤០គីឡូក្រាម ទៅកាន់ប្រទេសវៀតណាម បើយោងតាមបញ្ជីនាំចេញឈើរបស់ក្រុមហ៊ុន ដែលបានចុះផ្សាយថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣។[4]

ផ្អែកតាមទិន្នន័យនាំឈើចេញខាងលើ ដែលផ្ទុយពីការអនុញ្ញាតរបស់រាជរដ្ឋាភិបាលកម្ពុជា ខណៈអង្គការជាតិ-អន្តរជាតិ និងសហគមន៍មូលដ្ឋាន ធ្លាប់រកឃើញបន្តបន្ទាប់ពីការកាប់បំផ្លាញព្រៃឈើនៅក្នុងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស។ ដើម្បីរក្សាបាននូវនិរន្តរភាពធនធានធម្មជាតិនៅកម្ពុជា ព្រមទាំង តបនឹងសេចក្តីព្រួយបារម្ភខាងលើ យើងខ្ញុំទាំងអស់គ្នាដែលជាសមាគម អង្គការមិនមែនរដ្ឋាភិបាល សហជីព សហគមន៍មូលដ្ឋាន និងក្រុមយុវជន ស្នើសុំដល់រាជរដ្ឋាភិបាលកម្ពុជាលុបអាជ្ញាប័ណ្ណអនុញ្ញាតការនាំឈើចេញ របស់ក្រុមហ៊ុនអង្គរ ផ្លាយវូត ខូ អិលធីឌី និងធ្វើការស៊ើបអង្កេតអំពីការនាំចេញប្រភេទឈើកម្រដែលផ្ទុយពីច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទៅបរទេស៕

---

[1] វិទ្យុអាស៊ីសេរី, *ក្រុមហ៊ុនអង្គរផ្លាយវូតនៅតែបន្តនាំចេញឈើកម្រទៅលក់នៅក្រៅប្រទេស*, Website: https://shorturl.at/dilKS ។

[2] សេចក្តីសម្រេចរបស់ទីស្តីពីការគណៈរដ្ឋមន្ត្រី, លេខ ៧៣៩ ស.ជ.ណ, ១៥ ធ្នូ ២០២១។

[3] សេចក្តីសម្រេចរបស់ទីស្តីពីការគណៈរដ្ឋមន្ត្រី, លេខ ១២២០ ស.ជ.ណ, ១៨ វិច្ឆិកា ២០១៦។

[4] បញ្ជីមុខទំនិញនាំចេញរបស់ក្រុមហ៊ុន អង្គរផ្លាយវូត ខូ អិលធីឌី, ០០៨/២២, ១៦ មីនា ២០២២។

***ទំនាក់ទំនងសាកសួរព័ត៌មានបន្ថែម៖***

**លោក ហេង គឹមហុង** ប្រធានផ្នែកកម្មវិធីស្រាវជ្រាវ និងតស៊ូមតិនៃសមាគមបណ្ដាញយុវជនកម្ពុជា
តាមរយៈលេខទូរស័ព្ទ 0967888368 / 092667599

**លោក អើត សារ៉ាយ** ប្រធានសមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ
តាមរយៈលេខទូរស័ព្ទ 096 242 4393

***សេចក្តីថ្លែងការណ៍នេះគាំទ្រដោយ៖***

| | | |
|---|---|---|
| 1. | សមាគមបណ្ដាញយុវជនកម្ពុជា | CYN |
| 2. | សមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ | KSILA |
| 3. | អង្គការសម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម | CISA |
| 4. | សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា | ADHOC |
| 5. | មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស | CENTRAL |
| 6. | សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្ម កម្ពុជា | CFSWF |
| 7. | គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា | COMFREL |
| 8. | សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនការស៊ីណូណាហ្គាវើលដ៍ | LRSU |
| 9. | សហព័ន្ធសហជីពកម្មករនយោជិតវិស័យទេសចរណ៍កម្ពុជា | CTWUF |
| 10. | សហព័ន្ធសហជីពឯករាជ្យ | INTUFE |
| 11. | មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព | PDP-Center |
| 12. | សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ | IDEA |
| 13. | អង្គការអភិវឌ្ឍន៍ធនធានយុវជន | YRDP |
| 14. | វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា | CID |
| 15. | សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស | LICADHO |
| 16. | ក្រុមយុវជនចលនាមាតាធម្មជាតិ | MNC |
| 17. | បណ្ដាញសហគមន៍ព្រៃឡង់ | PLCN |
| 18. | ក្លឹបមិត្តអ្នកអានសៀវភៅ | រាជធានីភ្នំពេញ |
| 19. | ក្រុមយុវជន The Forest Guad | រាជធានីភ្នំពេញ |
| 20. | សហគមន៍ជនជាតិដើមភាគតិចបាក្លែ | ខេត្តក្រចេះ |
| 21. | សហគមន៍ព្រៃឈើក្បាលខ្លា | ខេត្តកំពង់ធំ |
| 22. | សហគមន៍នេសាទបឹងធំ | ខេត្តកំពង់ធំ |
| 23. | សហគមន៍ព្រៃមេត្តាធម្មជាតិ | ខេត្តកំពង់ស្ពឺ |
| 24. | សហគមន៍រងគ្រោះដីធ្លីតានូន | ខេត្តកោះកុង |